ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ឧបទ្ទវហេតុអគ្គិភ័យនៅរោងចក្រ ហ្វ័រម៉ាត (ខេមបូឌា) ខូ អិលធីឌី
# FOREMART (CAMBODIA) CO., LTD.

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិត និងសាធារណជន ឱ្យបានជ្រាបថា នៅវេលាម៉ោង ៦:៣០នាទីល្ងាច ថ្ងៃអង្គារ ទី១១ ខែកុម្ភៈ ឆ្នាំ២០២៥ មានករណីអគ្គិភ័យឆាបឆេះអគាររោងចក្រ **ហ្វ័រម៉ាត (ខេមបូឌា) ខូ អិលធីឌី** ដែលមានកម្មករនិយោជិតបម្រើការងារសរុប ៤៦៦នាក់ (ស្រី ៣១០នាក់) មានទីតាំងស្ថិតនៅភូមិអន្លង់គងថ្មី សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ។ បន្ទាប់ពីទទួលបានព័ត៌មានភ្លាម ថ្នាក់ដឹកនាំ មន្ត្រីជំនាញក្រសួង និងមន្ត្រី ប.ស.ស. បានចុះទៅដល់កន្លែងកើតហេតុ និងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធប្រកបដោយការយកចិត្តទុកដាក់ខ្ពស់បំផុត។ ករណីអគ្គិភ័យនេះ ពុំមានបណ្តាលឱ្យកម្មករនិយោជិតណាមួយរងគ្រោះថ្នាក់នោះទេ ហើយបច្ចុប្បន្ន សមត្ថកិច្ចកំពុងបន្តស៊ើបអង្កេតរកមូលហេតុបង្កឱ្យមានអគ្គិភ័យនេះ។

នៅព្រឹកថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៥ នេះ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ត្រីជំនាញក្រសួង បានបន្តចុះពិនិត្យស្ថានភាពខូចខាតរបស់រោងចក្រ ដើម្បីសាកសួរសុខទុក្ខបងប្អូនកម្មករនិយោជិត និងធានាដោះស្រាយប្រាក់ឈ្នួលលើកទី១ និងអត្ថប្រយោជន៍ផ្សេងៗ ជូនបងប្អូនកម្មករនិយោជិត នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៥ ខាងមុខនេះ បន្ថែមពីនោះ បងប្អូនកម្មករនិយោជិតនៅតែអាចប្រើប្រាស់បណ្ណ ប.ស.ស. បានជាធម្មតា ជាពិសេស អត្ថប្រយោជន៍នៅពេលពិនិត្យផ្ទៃពោះ និងសម្រាលកូន។ ទន្ទឹមនេះ ក្រសួងសូមសម្តែងនូវការសោកស្តាយបំផុតចំពោះឧបទ្ទវហេតុអគ្គិភ័យនេះ និងសូមថ្លែងអំណរគុណដល់អាជ្ញាធរមានសមត្ថកិច្ច កម្លាំងពន្លត់អគ្គិភ័យ ព្រមទាំងថ្នាក់ដឹកនាំក្រសួង ដែលបានចុះអន្តរាគមន៍នៅទីតាំងកើតហេតុយ៉ាងសកម្មប្រកបដោយការយកចិត្តទុកដាក់បំផុត និងគ្រប់គ្រងស្ថានភាពអគ្គិភ័យមិនឱ្យរាលដាលដល់រោងចក្រ និងកន្លែងផ្សេងទៀត។

ក្នុងករណីបងប្អូនកម្មករនិយោជិតចង់ស្វែងរកការងារ បងប្អូនក៏អាចចាប់យកឱកាសការងារថ្មី តាមរយៈមជ្ឈមណ្ឌលការងារចល័តនៃទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) ដោយនឹងចុះផ្សព្វផ្សាយពីឱកាសការងារ និងមានមន្ត្រីរង់ចាំចុះឈ្មោះស្វែងរកការងារធ្វើភ្លាមៗជូនបងប្អូនកម្មករនិយោជិត នៅក្បែរទីតាំងរោងចក្រ **ហ្វ័រម៉ាត (ខេមបូឌា) ខូ អិលធីឌី** ដើម្បីឱ្យបងប្អូនទទួលបានឱកាសការងារថ្មីជាមួយនឹងរោងចក្រ សហគ្រាស នៅក្បែរតំបន់ដែលបងប្អូនរស់នៅស្រាប់ ឬទំនាក់ទំនងមកប្រព័ន្ធ Hotline លេខ "១២៨៦" ឬ "១២៩៧" ឬលេខទូរសព្ទ ០៧៧ ២៣២ ៣៧៨/០១៦ ៧៨៦ ៦៥៥ (តេឡេក្រាម)។

អាស្រ័យហេតុនេះ សូមបងប្អូនកម្មករនិយោជិត និងសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ១៥កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៥